# សិលាចារឹកទួលកំណប់ត្រពាំងថ្ម K.១៣៣-២

## ១- ព័ត៌មានទូទៅ

ត្រពាំងថ្ម ឬ ទួលកំណប់ត្រពាំងថ្ម មានទីតាំងស្ថិតនៅភូមិដូនមាស ឃុំសំបូរ ស្រុកសំបូរ ខេត្តក្រចេះ គឺជាប្រាសាទមួយស្ថិតនៅក្នុងក្រុមប្រាសាទនានា នាអតីតក្រុងសម្ភុបុរៈ។ ទីតាំងទួលនេះ មានចម្ងាយនៅខាងជើងឃុំសំបូរ ប្រមាណ២គីឡូម៉ែត្រ នៅឆៀងខាងវត្តវិហារសសរមួយរយប្រមាណ ១,៥គីឡូម៉ែត្រ ខាងកើតទន្លេមេគង្គ ៨០០ម៉ែត្រ និងអាគ្នេយ៍ភូមិដូនមាសប្រមាណ ៦០០ម៉ែត្រ។ នៅទួលនេះ មានគ្រឹះប្រាសាទឥដ្ឋចំនួន៣ រត់លើអក្សជើងត្បូង និងនៅជុំវិញនោះ មានត្រពាំងជាច្រើនផង។[១] នៅទីនេះ គេធ្លាប់រកឃើញសិលាចារឹកចំនួន ២ផ្ទាំង ចុះលេខបញ្ជីសារពើភណ្ឌ K.១៣៣ និងK.២៨០។ សិលាចារឹកចុះលេខ K.២៨០ ចុះលេខសម្គាល់ស្ទួន គឺដើមឡើយចុះលេខ K.១៣៣-១ និងមួយផ្ទាំងដែលរកឃើញនៅទីតាំងនេះដូចគ្នា ចុះលេខK.១៣៣-២។ ប៉ុន្តែក្រោយមក ប្រហែលជាមានបញ្ហា ក្នុងការរៀបចំឯកសារ ទើបប្រទ្បំចុះលេខសិលាចារឹក K.១៣៣-១ ម្តងទៀតជា K.២៨០ បន្ថែមទៀត។ ករណីបែបនេះ យើងឃើញមានច្រើនដែរ ក្នុងការចុះបញ្ជីលេខសិលាចារឹកខ្មែរ។ នៅក្នុងអត្ថបទនេះយើងយកតែសិលាចារឹក K.១៣៣-២ ប៉ុណ្ណោះ មកផ្សព្វផ្សាយ។ មូលហេតុដែលយើងយកសិលាចារឹកនេះមកចុះផ្សាយ ដោយហេតុពុំទាន់មានអត្ថបទសិលាចារឹកនេះចុះផ្សាយជាភាសាខ្មែរផង និងត្រូវផ្ទៀងផ្ទាត់អំណានសិលាចារឹកនេះ បន្ថែមលើការសិក្សារបស់អ្នកស្រាវជ្រាវបរទេសកន្លងមកផង។

សិលាចារឹកនេះ ធ្លាប់បានសិក្សាដោយលោក ហ្សក សេដេស ចុះផ្សាយនាឆ្នាំ១៩៥៣ នៅក្នុងសៀវភៅសិលាចារឹកនៃប្រទេសកម្ពុជា ក្បាលទី៥ ទំព័រ៨១-៨២។ នៅក្នុងការចុះផ្សាយនោះ លោកគ្រាន់តែអានអំណាននោះជាអក្សរឡាតាំង និងសង្ខេបអត្ថន័យ ដោយពុំបកប្រែសិលាចារឹកនោះឡើយ ដោយហេតុថាសិលាចារឹកនោះ គ្រាន់តែជាបញ្ជីខ្ញុំបម្រើ

[១] https://cisark.mcfa.gov.kh/core/showsite.php?id=333

អត្ថបទដោយៈ ហ៊ុន ឈុនតេង

ថ្វាយចំពោះប្រាសាទស្រីវិមលេស្វរ (គ្រីវិមលេគ្វរ) ដោយម្រតាញរុទ្រពិន្ទុ (រុទ្រវិន្ទុ)។ យ៉ាងនេះក្តី សេចក្តីសង្ខេបរបស់លោក គឺគ្រប់គ្រាន់ល្មមនឹងយល់សេចក្តីទាំងស្រុងនៃសិលាចារឹកនេះទៅហើយ។

ផ្ទាំងសរសេរចារឹកនេះ គឺជាមេទ្វារប្រាសាទ ដែលបាក់ពាក់កណ្តាលផ្នែកខាងក្រោមនៅសល់តែផ្នែកខាងលើដែលមានអក្សរចារឹកចំនួន៧បន្ទាត់។ អត្ថបទនេះ ចារឹកជាភាសាខ្មែរនិងអក្សរសម័យមុនអង្គរ និងពុំមានចុះកាលបរិច្ឆេទឡើយ ប៉ុន្តែលោក សេដេស បានសន្និដ្ឋានតាមទម្រង់អក្សរ គឺគួរតែស្ថិតនៅក្នុងស.វ.ទី៨។ បច្ចុប្បន្ន ផ្ទាំងសិលាចារឹកនេះ គេរក្សាទុកនៅខាងមុខចេតិយព្រះនាងក្រពុំឈូក ក្នុងវត្តសសរ១០០ ខេត្តក្រចេះ។

## ២- អត្ថបទដើមជាភាសាខ្មែរទំនើប

១- (ក្ញុំ)អំនោយិម្រតាញ៑រុទ្រវិន្ទុអាយិតវ្រ(ះ)កម្រតាង៑អញ៑គ្រីវិមលេគ្វរ

២- វាក្វមិ១វាគីលភក្តិ១វាក្ញុម្នគុបិ[២]១វាត្វៅ[៣]១វាបង្កើតិ១វាប្រីតិ១វាប្តមិ[៤](១)

៣- វាសំអបិ[៥]១វាកន្ទាង៑១វាជាហ្វលិ[៦]១វាភទ្រចនិ១វាត្បុយិ១វាត្បិតិ១វាត្យោនិ(១)

៤- វាខលសង្គ[៧]១វាកភុបិ[៨]១វាទុជំន១កុសុមតី[៩]១កោនិកុ៤កុក្តី១កោនិកុ

៥- កុគុរុកម្ម៑១កុមលិ១កោនិកុ១កុប្កាយិ១កោនិកុ១កុចូបិ១កុប្រុក៑១កុក្តោមិ(១)

៦- កុសមុទ្រ១កោនិកុ១កុស្តោយិ១កុមធុករី១កុកថារ៉ាំសិរិ១កុស្រចិ១កោនិកុ(១)

---

[២] លោក សេដេស (១៩៥៣) អានជា «ក្ញុម្ភគុហ»។

[៣] លោក សេដេស (១៩៥៣) អានជា «ត្កៅ»។

[៤] លោក សេដេស (១៩៥៣) អានជា «ស្តម»។

[៥] លោក សេដេស (១៩៥៣) អានជា «សអបិ»។

[៦] លោក សេដេស (១៩៥៣) អានជា «ជហ្វលិ»។

[៧] លោក សេដេស (១៩៥៣) អានជា «ឰលសង្គ» ប៉ុន្តែលោកក៏ផ្តល់ជម្រើសអំណានផ្សេងទៀត ដូចជា «ខល–/ចេល–» ផងដែរ។

[៨] លោក សេដេស (១៩៥៣) អានជា «កកបិ»។

[៩] លោក សេដេស (១៩៥៣) អានជា «សុមតិ»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

៧- ស្រែត្មៃកុ៨០៙ស្រែអំនោយិញ្ជតវ្រះកំម្រតាងអញ

## ៣- អត្ថបទប្រែសម្រួល

ខ្ញុំបម្រើជាអំណោយរបស់ម្រតាញរុទ្រពិន្ទុ (ថ្វាយ)ចំពោះព្រះគម្តែងអញស្រីវិមលេសូរ (មានដូចជា) វា[១០]ក្តម១ វាសីលកក្តិ១ វាក្រឹស្ណគុប១ វាថ្ងៅ១ វាបង្កើត១ វាប្រីតិ១ វាប្តម១ វាសំអប១ វាកន្តាង១ វាជាហ្វល១ វាកទ្រចន១ វាត្បុយ១ វាត្បិត១ វាត្បោន១ វាខលសង្គ១ វាកកុប១ វាទុជ៌ន១ កុ[១១]សុមតី១ (និង)កូននាង៤(នាក់) កុក្តី១ (និង)កូននាង កុគុរុកម្ម៌១ កុមលិ១ (និង)កូននាងម្នាក់ កុផ្កាយ១ (និង)កូននាងម្នាក់ កុច្ងប១ កុប្រុក១ កុក្តោម១ កុសមុទ្រ១ (និង)កូននាងម្នាក់ កុស្តោយ កុមធុករី១ កុកថាពុំសេរ១ កុស្រច១ (និង)កូននាងម្នាក់។ ស្រែថ្ងៃនារី៨០(នាក់) (ជា)ស្រែអំណោយ(ថ្វាយ)ដល់ព្រះគម្តែងអញ។

## ៤- សរុបសេចក្តី

ជាសរុបរួម សិលាចារឹកមួយផ្ទាំងនេះ គឺជាបញ្ជីអ្នកបម្រើព្រមទាំងស្រែថ្វាយចំពោះប្រាសាទ។ នេះគឺជាកម្មវត្ថុទូទៅមួយ ដែលយើងតែងឃើញមាននៅស្ទើរតែគ្រប់សិលាចារឹកទាំងអស់ ដ្បិតថាកម្មវត្ថុនៃសិលាចារឹក គឺកត់ត្រាអំពីអំពើបុណ្យ។ ទោះជាសេចក្តីនៃសិលាចារឹកខ្លះ ពុំបង្ហាញអំពីអំពើបុណ្យ ដូចជាអក្សរឬគំនូសសញ្ញាខ្លីៗជាដើម ដែលពុំបង្ហាញអ្វីវែងឆ្ងាយអំពីបុណ្យក្តី ក៏អក្សរនោះចារកត់ចំណាំលើថ្មដែលយកមកកសាងប្រាសាទដែរ។

ការផ្ទៀងផ្ទាត់ឡើងវិញ នូវអំណាននិងសេចក្តីបកប្រែ ដែលអ្នកសិក្សាជាន់មុនបានសិក្សារួចមកនោះ មានទិន្នន័យខ្លះអាចឱ្យយើងបកស្រាយជាថ្មី លើសេចក្តីសន្និដ្ឋានដែលមានកន្លងមកផងដែរ។ នេះជាចំណុចសំខាន់មួយសម្រាប់មជ្ឈដ្ឋានសិក្សាខ្មែរ។

[១០] វា ជាឋានន្តរនាមសម្គាល់អ្នកបម្រើភេទប្រុស។

[១១] កុ ជាឋានន្តរនាមសម្គាល់អ្នកបម្រើស្រី។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

## ៥- ពន្យល់ពាក្យ

| | |
|---|---|
| ក្ញុំ | ខ្ញុំបម្រើ, អ្នកបម្រើនៅប្រាសាទឬវត្តអារាម។ |
| អំនោយ៑ | អំណោយ, តង្វាយ។ |
| ម្រតាញ៑ | ឋានន្តរនាមរបស់មន្ត្រីឬព្រាហ្មណ៍នាសម័យមុនអង្គរ។ |
| អាយ៑ត/ព្ទត | អាយ៑ + ត = ដល់ ចំពោះ ... ។ |
| វ្រះកម្រតាង៑អញ៑ | ឋានន្តរនាមរបស់ទេព និងព្រះមហាក្សត្រ។ |
| វា | ឋានន្តរនាមសម្គាល់អ្នកបម្រើភេទប្រុស។ |
| កុ | ឋានន្តរនាមសម្គាល់អ្នកបម្រើភេទស្រី។ |
| កោន៑ | កូន។ |
| ស្រេ | ស្រែ។ |
| ត្លៃ | ថ្លៃ តម្លៃ។ |

### ឯកសារយោង


CIK-EFEO (Producer). (2023). Télécharger l'Inventaire Excel mis à jour en 2023. Retrieved from https://cik.efeo.fr/inventaire-cik-des-inscriptions-khmeres/

Cœdès, George. (1953). Inscription de Trapăṅ Thma (Saṃbór). In *Inscription du Cambodge* (Vol. V, pp. 198-199). Paris: Editions de Boccard.

https://cisark.mcfa.gov.kh/core/showsite.php?id=333

http://sealang.net/ok/corpus.htm

# បញ្ជីរូបភាព



សិលាចារឹកត្រពាំងថ្ម K.១៣៣-២ តម្កល់ទុកនៅខាងមុខចេតិយព្រះនាងក្រពុំឈូក
(រូបថត៖ ហ៊ិន ឈុនតេង)



សិលាចារឹកត្រពាំងថ្ម K.១៣៣-២ តម្កល់ទុកនៅខាងមុខចេតិយព្រះនាងក្រពុំឈូក
(រូបថត៖ ហ៊ិន ឈុនតេង)



សំណៅផ្តិតសិលាចារឹកត្រពាំងថ្ម K.១៣៣-២ (រូបថត៖ EFEO)




កំណត់សម្គាល់សិលាចារឹកត្រពាំងថ្ម K.១៣៣-២ (រូបថត៖ EFEO)

អត្ថបទដោយ៖ ហ៊ិន ឈុនតេង



ទួលកំណាប់ត្រពាំងថ្ម (រូបថត៖ CISARK)



ទួលកំណាប់ត្រពាំងថ្ម (រូបថត៖ CISARK)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង